

# ដុសធ្មេញមិន សប្បាយទេ!

Srividhya Venkat

Anupama Ajinkya Apte

letsreadasia.org



ពេល រ៉ូហាន ភ្ញាក់ពីគេង រ៉ូហាន
ចាប់ផ្តើមលេងជាមួយឆ្កែរបស់ខ្លួន
ឈ្មោះ ជីមមី។ បងស្រីរបស់ រ៉ូហាន
ឈ្មោះ រីយ៉ា បាននិយាយទៅកាន់ រ៉ូ
ហាន ថា "អូនត្រូវដុសធ្មេញជាមុនសិន
មុននឹងលេងជាមួយ ជីមមី!"





"ខ្ញុំមិនចង់ដុសធ្មេញទេ! ជីមមី មិន ដុសធ្មេញរបស់វាផង!" "សត្វក៏ថែរក្សាធ្មេញរបស់ពួកវាដែរ ប៉ុន្តែក្នុងវិធីផ្សេងទៀត! យើងត្រូវតែដុសធ្មេញរបស់យើងដើម្បីការពារពីមេរោគផ្សេងៗ!" "មេរោគ?" "មេរោគគឺជាពពួកសត្វល្អិតតូចៗដែលយើងមិនអាចមើលឃើញឡើយ ។ ប្រសិនបើមិនដុសធ្មេញជាប្រចាំទេ មេរោគនឹងនៅក្នុងមាត់របស់យើង ហើយធ្វើឲ្យយើងឈឺធ្មេញ!" "អូយ" "ត្រូវហើយ! ដូច្នេះហើយយើងត្រូវថែទាំធ្មេញរបស់យើងដោយដុសធ្មេញពីរដងក្នុងមួយថ្ងៃ គឺនៅពេលព្រឹក និងពេលយប់" "ប៉ុន្តែ



ដុសធ្មេញអត់សប្បាយទេ!” ”បងនឹងប្រាប់អូនរឿងសម្ងាត់មួយ” រ៉ូហាន ឮហើយ ញញឹម។





ម៉ាក់ស្រែកប្រាប់ថា "ដល់ម៉ោងហូប
អាហារពេលព្រឹកហើយ!"

រីយ៉ា ក៏និយាយទៅកាន់ រ៉ូហាន ថា "មុន
យើងហូបអាហារពេលព្រឹក យើងត្រូវ
ធ្វើអ្វីមុនសិន?...យើងត្រូវលាងដៃ!"

ប៉ុន្តែ ជីមមី មិនដែលលាងដៃរបស់វាផង!"

រីយ៉ា សើច ហើយនិយាយទៅកាន់ប្អូនប្រុសរបស់ខ្លួនថា "ជីមមី មិនប្រើក្រញាំរបស់វា ដើម្បីស៊ីអាហារនោះទេ។ ពួកយើងប្រើប្រាស់ដៃ ដើម្បីហូបអាហារ ដូច្នេះយើងត្រូវលាងដៃជាមួយសាប៊ូ ដើម្បីសំលាប់មេរោគ។" "មេរោគនៅជាប់ដៃរបស់យើង?" "មេរោគគឺនៅគ្រប់ទីកន្លែង!" អាឈីស...! រីយ៉ា យកដៃខ្ទប់មាត់ ពេលនាងកណ្តាស់ ។



រ៉ូហាន ប្រាប់បងស្រីរបស់ខ្លួនថា "កុំធ្វើអីចឹង! លោកគ្រូរបស់ខ្ញុំប្រាប់ថាយើងគួរយកដៃអាវ មិនមែនយកដៃ



របស់យើងមកខ្ទប់ ពេលយើងកណ្តាស់
នោះទេ។" "ហេតុអ្វីទៅ?" "ពីព្រោះ
នៅពេលដែលយើងកណ្តាស់ដាក់ដៃ
យើង មេរោគគឺជាប់នឹងដៃរបស់យើង
។ ប្រសិនបើមិនលាងដៃទេ យើងនឹង
ធ្វើឱ្យមេរោគរាលដាលទៅដល់អ្នកដទៃ
នឹងធ្វើឱ្យពួកគេឈឺ។"



”មេរោគមកហើយ!” រីយ៉ាស្រែក ហើយដេញចាប់រ៉ូហានជាមួយដៃកខ្វក់របស់ខ្លួន។



ក្រោយមក រីយ៉ា បង្ហាញ រ៉ូហានពីវិធី សាស្ត្រលាងដៃឱ្យបានត្រឹមត្រូវ។

"ជាដំបូង យើងលាងដៃជាមួយនឹងទឹក ឱ្យសើម រួចបិទទឹក។ បន្ទាប់មកលាង ជាមួយសាប៊ូ ដោយត្រដុសបាតដៃនឹង បាតដៃជាមួយគ្នា រួចបត់ម្រាមដៃ និង ម្រាមដៃចូលគ្នា រួចត្រដុសឱ្យបានសព្វ ក្នុងរយៈពេល២០ វិនាទី។ នៅពេល នេះ យើងលាងសាប៊ូចេញជាមួយនឹង ទឹក ហើយជូតដៃឱ្យស្ងួត។ " "តែវា យូរណាស់!" រីយ៉ា សួរ រ៉ូហាន ថា "នៅ ចងចាំរឿងសម្ងាត់បងប្រាប់ឬអត់?"





នៅពេល រីយ៉ា និង រ៉ូហាន ត្រលប់មក ផ្ទះ បន្ទាប់ពីរត់លេងរួច រីយ៉ា សួរ រ៉ូហាន ថា ”តើយើងត្រូវធ្វើអ្វីមុនសិន?”

ម៉ាក់និយាយបែបលេងសើច ”លេង ថែមទៀត?”

”មិនមែនទេម៉ាក់! យើងត្រូវងូតទឹក ជាមុនសិន។”

”ម៉ាក់ដឹងដែរទេថា មេរោគនៅគ្រប់ ទីកន្លែង? យើងមិនអាចមើលឃើញ តែមេរោគនៅជាប់ស្បែក និង សម្លៀកបំពាក់របស់យើង!”

”អ៊ីចឹង! យើងត្រូវងូតទឹក និងលាងដៃ ជារៀងរាល់ថ្ងៃ ដើម្បីសម្លាប់មេរោគ!”



ម៉ាក់និយាយថា "ដំបូងយើងត្រូវឱ្យខ្លួនយើងសើមសិន រួចចាប់ផ្ដើមដុសជាមួយសាប៊ូ។" រ៉ូហាន និង រីយ៉ា សើចក្អាកក្អាយ ដោយសារតែពេលម៉ាក់ដុសសាប៊ូ រសើបមែនទែន។ បន្ទាប់ពីដុសជាមួយសាប៊ូសព្វពេញរាងកាយ ម៉ាក់និយាយថា "នៅពេលនេះ យើងចាប់ផ្ដើមលាងសម្អាតសាប៊ូជាមួយទឹក។ បន្ទាប់មក យើងជូតខ្លួនឱ្យស្ងួតជាមួយនឹងកន្សែងស្អាត។"



ប៉ាសួរថា ”តើកូនៗចង់ស្តាប់រឿងនិទាន
ដែរឬទេ?”



រីយ៉ា រំលឹក រ៉ូហាន ថា ”តើយើងត្រូវធ្វើអ្វីមួយសិន?...រៀបចំទុកដាក់របស់យើងសិន!”

រ៉ូហាន សួរបងស្រីរបស់ខ្លួនថា ”តើយើងត្រូវតែធ្វើ? ចុះបើអត់ធ្វើបានឬអត់?”

រីយ៉ា និយាយតបទៅវិញ ”ចាំអត់ កាលពីម្សិលមិញ អូនរកបាល់អត់ឃើញ? ពេលយើងទុកដាក់របស់ឱ្យមានសណ្តាប់ធ្នាប់ យើងនឹងមានភាពងាយស្រួលក្នុងការរកវានៅពេលក្រោយ!”

”រួមទាំងធ្វើឱ្យផ្ទះរបស់យើងមាន



សណ្ដាប់ធ្នាប់ទៀតផង!”

ប៉ានិយាយទាំងសប្បាយចិត្តថា ”កូនៗ ពិតជាឆ្លាតមែន!”

រីយ៉ា និយាយថា ”ប៉ា! មានរឿងមួយ យើងត្រូវធ្វើសិន!”

និយាយរួច រីយ៉ា ដឹកដៃ រ៉ូហាន មក ជាមួយ។





ប៉ុន្មាននាទីក្រោយមក ម៉ាក់ និងប៉ាលឺសូរចម្រៀងចេញពីបន្ទប់ទឹក។

ប៉ានិយាយថា "ប៉ាដឹងអំពីរឿងសម្ងាត់របស់កូនហើយ! កូនច្រៀងបណ្ដើរដុសធ្មេញបណ្ដើរ អ៊ីចឹងធ្វើឱ្យការដុសធ្មេញសប្បាយ។"

"ពួកយើងក៏ច្រៀង ពេលយើងលាងដៃដែរ!"

ម៉ាក់និយាយថា "នេះពិតជាគំនិតល្អមែន!"

រ៉ូហាន និង រីយ៉ា សប្បាយចិត្តនឹងការថែទាំខ្លួនឯង។ ចុះប្អូនវិញ?







មេរោគថា ភាពកខ្វក់គឺជារឿងល្អ
និងសប្បាយ! តែខ្ញុំថាខ្ញុំដុសធ្មេញ
និងលាងដៃ! ខ្ញុំជឿជាក់ថាខ្ញុំជា
អ្នកឈ្នះ! មេរោគតបវិញថាងូតទឹក
គឺជាពេលវេលាដ៏ខ្ជះខ្ជាយមួយ! ខ្ញុំ
ប្រាប់វិញថាខ្លួនក្រអូបជាមួយនឹងសាប៊ូ
ពិតជាសប្បាយរីករាយ! មេរោគអាក្រក់
ប្រាប់ថា មិនចាំបាច់រៀបចំទុកដាក់
របស់ទេ! ផ្ទះមើលទៅស្អាតនៅពេល
របស់រាយប៉ាយ! ខ្ញុំតបវិញ ខ្ញុំរៀបចំ
ទុកដាក់ ព្រោះខ្ញុំស្រលាញ់ទ្រព្យរបស់
ខ្ញុំ។ ខ្ញុំសប្បាយរីករាយជាងមុន!
សប្បាយរីករាយ! សប្បាយរីករាយ!

នៅពេលនេះ ប្អូនៗតែងបទចម្រៀង



ខ្លួនឯង និងច្រៀងបទចម្រៀងនោះ
នៅពេលធ្វើការងារធុញទ្រាន់។





Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

Original Story
Brushing Is No Fun!, author: Srividhya Venkat. illustrator: by Anupama Ajinkya Apte. Published by Pratham Books, https://storyweaver.org.in/stories/7263-brushing-is-no-fun © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/

Contributing translators: Luy Veasna, Solyda Say, and Nhean Socheat